# សេចក្តីជូនដំណឹងស្តីពីការប្រកាសជ្រើសរើស
# អ្នកផ្តល់សេវាបច្ចេកទេសឯកជនសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

| | |
|---|---|
| ឈ្មោះគម្រោង | រដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ (LGCC) តំណាក់កាលតភ្ជាប់ |
| មុខតំណែងជ្រើសរើស | អ្នកផ្តល់សេវាបច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ សង្កាត់ |
| រយៈពេលផ្តល់សេវា | ចាប់ពី ៨-១២ ខែ |

## សាវតាគម្រោង

គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ ដំណាក់កាលតភ្ជាប់ ក្នុងគោលបំណងពង្រឹងរដ្ឋបាលមូលដ្ឋានក្នុងការរៀបចំផែនការ និងថវិកាឆ្លើយតបទៅនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ និងដើម្បីជាការឆ្ពោះទៅពង្រីកខេត្ត ស្រុក គោលដៅនៅជំហានបន្ត។ គម្រោងរដ្ឋបាលមូលដ្ឋាន តាមរយៈមូលនិធិ PBCR គាំទ្រគម្រោងមូលនិធិឃុំ ប្រមាណ១/៣នៃមូលនិធិវិនិយោគឃុំនីមួយៗ សម្រាប់គាំទ្រគម្រោងហេដ្ឋារចនាសម្ព័ន្ធ កិច្ចការរដ្ឋបាលស្រុកសម្រាប់គាំទ្រគម្រោង និងសេវាគាំទ្របច្ចេកទេសឯកជនសម្រាប់ការសិក្សាឋានលេខា គ្រោងការគម្រោង កិច្ចលទ្ធកម្ម និងត្រួតពិនិត្យការងារសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំគោលដៅ។ គោលបំណងសំខាន់នៃវិភាជន៍ថវិកាគាំទ្រ គម្រោងមូលនិធិឃុំ គឺគាំទ្រដល់ការអនុវត្តសកម្មភាពជាអាទិភាពរបស់ឃុំដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ឃុំ (CDP/DCP) និងកម្មវិធីវិនិយោគឃុំ (CIP/DIP) និងសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ថវិកាដែលគាំទ្រពីកម្មវិធីនឹងធ្វើការវិភាជន៍ប្រមាណ ៨៥ភាគរយ សម្រាប់ការវិនិយោគទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច អតិបរិមា៣ភាគរយ នៃថវិកាវិនិយោគត្រូវវិភាជន៍សម្រាប់ចំណាយទៅលើកិច្ចការរដ្ឋបាល និងចំនួនអតិបរិមា ១២ភាគរយនៃថវិកាត្រូវវិភាជន៍សម្រាប់ការផ្តល់សេវាបច្ចេកទេសឯកជន។

ក្នុងពេលបច្ចុប្បន្ននេះតម្រូវការផ្តល់សេវាបច្ចេកទេសនេះរួមមានការងារ ការប្រមូលទិន្នន័យ ព័ត៌មាននៅមូលដ្ឋាន សិក្សាឋានលេខា គ្រោងការគម្រោង ប៉ាន់ស្មានតម្លៃគម្រោង រៀបចំឯកសារដេញថ្លៃ គាំទ្រដំណើរការដេញថ្លៃ និងត្រួតពិនិត្យការអនុវត្តកិច្ចសន្យា។ល។ ការងារបច្ចេកទេសទាំងនេះបានប្រតិបត្តិតាមគោលការណ៍នៃសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (PIM)។ ដើម្បីគាំទ្រលើកិច្ចការនេះ កម្មវិធីត្រូវការជ្រើសរើសអ្នកផ្តល់សេវាបច្ចេកទេសឯកជនមានគុណសម្បត្តិគ្រប់គ្រាន់០១រូប ដើម្បីជួយក្រុមប្រឹក្សាឃុំ សង្កាត់ សម្រាប់ជំនួសឱ្យសេវាគាំទ្របច្ចេកទេសលើការងារការសិក្សា គ្រោងការ កិច្ចលទ្ធកម្ម និងត្រួតពិនិត្យការងារសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ សង្កាត់ ដែលផ្តល់ដោយមន្ត្រីគាំទ្របច្ចេកទេសនៃទីចាត់ការផែនការ និងវិនិយោគខេត្ត ក្នុងក្រុង ស្រុកគោលដៅនីមួយៗដូចខាងក្រោម៖

Scanned by CamScanner

| ល.រ | ស្រុកគោលដៅ | ឃុំ សង្កាត់ គោលដៅ | ចំនួនអ្នកជំនួយការបច្ចេកទេស |
| --- | --- | --- | --- |
| **ខេត្ត តាកែវ** | | | |
| ១ | ក្រុងដូនកែវ | សង្កាត់: បារាយណ៍, រកាក្នុង និង រកាក្រៅ | ១ |

## ២. គោលបំណង

គោលបំណងនៃសេវាបច្ចេកទេស គឺជាការផ្តល់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ នូវសេវាបច្ចេកទេសប្រកបដោយគុណភាពសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច។ តម្រូវការផ្តល់សេវាបច្ចេកទេសនេះរួមទាំង ការប្រមូលទិន្នន័យ ព័ត៌មានបច្ចេកទេសនៅមូលដ្ឋាន សិក្សាលទ្ធភាពគម្រោង គ្រោងការគម្រោង ប៉ាន់ស្មានតម្លៃគម្រោង រៀបចំឯកសារដេញថ្លៃ គាំទ្រដំណើរការដេញថ្លៃ ឯកសារកិច្ចសន្យាសាងសង់ និងត្រួតពិនិត្យការអនុវត្តកិច្ចសន្យា។ល។ (មានលម្អិតក្នុងលក្ខខណ្ឌការងាររបស់អ្នកផ្តល់សេវាបច្ចេកទេស)។ គម្រោងនឹងត្រូវសាងសង់ដោយអ្នកទទួលការសាងសង់ ចុះកិច្ចសន្យាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយថវិកាមូលនិធិឃុំ សង្កាត់ និងថវិកាពី PBCR។

## ៣. តម្រូវការលក្ខណៈសម្បត្តិ និងបទពិសោធន៍

អ្នកផ្តល់សេវាបច្ចេកទេសឯកជន(TSC)ត្រូវមានលក្ខណៈសម្បត្តិយ៉ាងតិចមួយក្នុងចំណោមតម្រូវការខាងក្រោម៖

- ✓ យ៉ាងហោចណាស់មានកម្រិតជំនាញ ឬសញ្ញាបត្រវិស្វករជាងសាស្ត្រកសិកម្ម សំណង់ស៊ីវិល ឬជំនាញប្រហាក់ប្រហែល
- ✓ មានបទពិសោធន៍យ៉ាងតិច៣ឆ្នាំក្នុងការសិក្សាវាស់ស្ទង់ គ្រោងប្លង់គម្រោង ប៉ាន់ស្មានតម្លៃ ត្រួតពិនិត្យគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា ទំនប់ ប្រឡាយ សំណង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូច មធ្យម ឬស្រះ។ល។
- ✓ មានចំណេះដឹងស្តីពីហេដ្ឋារចនាសម្ព័ន្ធធន់ និងទប់ទល់នឹងអាកាសធាតុ និងគ្រោះមហន្តរាយ
- ✓ ចេះប្រើកុំព្យូទ័រដូចជាកម្មវិធី Word, Excel, AutoCAD និងប្រព័ន្ធអ៊ីនធឺណេត អ៊ីម៉ែល
- ✓ ត្រូវតែស្ថិតនៅ ឬមានឆន្ទៈធ្វើការនៅក្នុងស្រុកគោលដៅ
- ✓ មានសម្ភារៈ ឧបករណ៍សិក្សាបច្ចេកទេស និងយានជំនិះសម្រាប់ធ្វើដំណើរបានញឹកញាប់ទៅតាមឃុំគោលដៅ។
- ✓ បុគ្គលដែលមានចំណាប់អារម្មណ៍ត្រូវដាក់ពាក្យស្នើសុំ ប្រវត្តិរូបសង្ខេប និងបទពិសោធន៍ការងារ (CV)។ មុនពេលដាក់ពាក្យសូមពិនិត្យមើលលក្ខខណ្ឌការងារសម្រាប់ផ្តល់សេវាបច្ចេកទេសឯកជនដែលអាចរកពីក្រុមការងារកម្មវិធីថ្នាក់ខេត្ត ស្រុក ឬទាញយកបានគេហទំព័រគ.ជ.អ.ប www.ncdd.gov.kh

- ✓ ដាក់ពាក្យស្នើសុំ ប្រវត្តិរូបសង្ខេប និងបទពិសោធន៍ការងារ (CV) និងត្រូវបំពេញក្នុងលិខិតស្តីពីការសម្តែងចំណាប់អារម្មណ៍(ឧបសម្ព័ន្ធ ក.១) ច្រកក្នុងស្រោមសំបុត្រដាក់នៅតាមស្រុក ខេត្តគោលដៅខាងលើតាមរយៈក្រុមការងារកម្មវិធី។ រាល់ការដាក់ពាក្យស្នើសុំមិនអាចធ្វើតាមអ៊ីម៉ែលបានឡើយ។ ៦

Scanned by CamScanner

<table>
<tr><td colspan="2">
- កាលបរិច្ឆេទឈប់ទទួលពាក្យនៅម៉ោង ៥ និង៣០នាទី ល្ងាច ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៨<br>
- មានតែអ្នកដែលបានជាប់ក្នុងបញ្ជីសម្រាំងខ្លីនៃបេក្ខជន ប៉ុណ្ណោះនឹងត្រូវជូនដំណឹងអំពីការសំភាសន៍។
</td></tr>
<tr><td>សូមទំនាក់ទំនង<br>ព័ត៌មានបន្ថែម</td><td>លោកស្រី ប៊ុត ប៊ុណ្ណារី មន្ត្រីសម្របសម្រួលគម្រោងប្រចាំខេត្ត<br>ទូរស័ព្ទលេខៈ ០១៧ ៩៤០ ៦០០ អ៊ីមែលៈ</td></tr>
</table>

ថ្ងៃសុក្រ ៦កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១

ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៨

**អភិបាលក្រុង**

អភិបាលរង

ភុខ_អាណាន់

Scanned by CamScanner